# ទំនៀមទាញព្រ័ត្រថ្វាយអ្នកតាដើមសំរោង

អ្នកតាដើមសំរោង មានខ្ទមមួយស្ថិតនៅក្បែរព្រំប្រទល់ភូមិត្របែកពក និងភូមិព្រែកឫស្សី ប្របនឹងដៃទន្លេតូចមួយ ក្នុងឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្ដាល (រូបលេខ១)។ រៀងរាល់ឆ្នាំ អ្នកស្រុកតែងប្រារព្ធបុណ្យភូមិបីថ្ងៃ និងលេងទាញព្រ័ត្រក្នុងន័យជា "កិច្ចថ្វាយអ្នកតាដើមសំរោង" ពុំដែលខកខាន។ តាមទំនៀមរបស់អ្នកស្រុក ពិធីបុណ្យនេះតែងធ្វើក្រោយថ្ងៃចូលឆ្នាំរួចមួយរយៈខ្លីប៉ុណ្ណោះ[១] ហើយវត្ថុយកមកធ្វើព្រ័ត្រទាញថ្វាយអ្នកតា គឺ "ផ្ដៅ"។ ក្នុងថ្ងៃចុងក្រោយ អ្វីដែលគួរឱ្យពិចារណា គឺការប្រឹងទាញ "ផ្ដាច់ព្រ័ត្រ" នៅចំពោះមុខអ្នកតា ដ្បិត "ពេល" និង "កិច្ច" នេះហាក់បង្ហាញន័យឱ្យគិតបានថា "ដាច់" ពោលគឺដាច់ឆ្នាំចាស់ចូលឆ្នាំថ្មី។



*រូបលេខ១ រូបសំណាកអ្នកតាដើមសំរោង*

---

[១] បុណ្យក្នុងពេលនេះ តំបន់ខ្លះហៅថា "ឆ្លងចូលឆ្នាំ" ឬអ្នកស្រុកតំបន់អង្គរហៅថា "ឆ្លងចែត្រ"។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

មុននឹងឈានចូលអធិប្បាយលម្អិត អំពីទំនៀមទាញព្រ័ត្ររបស់អ្នកស្រុកកំពង់កុង យើងសូមរំឭកថា ក្នុងបរិបទខ្មែរ "ព្រ័ត្រ" ក៏ជាវត្ថុមួយមានតួនាទីសំខាន់ទាំងក្នុងជំនឿ និងទំនៀមទម្លាប់ប្រពៃណីដែរ។ អ្នកស្រាវជ្រាវមើលឃើញថា ព្រ័ត្រច្រើនសំដៅទៅលើខ្សែវេញដែលជាប់មាំមួន ពោលគឺមិនមែនគ្រាន់តែជាខ្សែចំណងធម្មតា ហើយក៏ខុសពីពួរ ដែលជាខ្សែវេញជាប់មាំដែរ តែសម្រាប់ចងវត្ថុធំ ឬធ្ងន់ឱ្យជាប់ទៅនឹងអ្វីមួយមិនឱ្យរបូតរសាត់។ ព្រ័ត្រអាចសំដៅទៅលើវត្ថុដែលមាននាទីពីរខុសគ្នា ម្យ៉ាងជាខ្សែសម្រាប់ទាក់សត្វ និងជាខ្សែសម្រាប់ទាញឱ្យដាច់ក្នុងការប្រកួតគ្នាដែលមានលក្ខណៈជាកិច្ចពិធីផង។[២] ដូច្នេះទើបយើងសង្កេតឃើញគេលេងទាញព្រ័ត្រក្នុងពិធីចូលឆ្នាំ ឆ្លងចែត្រ ឬឡើងអ្នកតា ហើយថ្ងៃចុងក្រោយគេត្រូវទាញព្រ័ត្រឱ្យដាច់។ ទំនៀមនេះ គេសង្កេតឃើញមានឧទាហរណ៍ខ្លះនៅតាមភូមិស្រុកមួយចំនួននៅកំពង់ធំ និងសៀមរាបដែរ។[៣]

ដូចបានបញ្ជាក់ត្រួសៗមកខាងលើ អ្នកស្រុកកំពង់កុងតែងបោចផ្ដៅវេញធ្វើព្រ័ត្រសម្រាប់លេងក្នុងពិធីបុណ្យភូមិ ដែលប្រារព្ធធ្វើបន្ទាប់ពីបុណ្យចូលឆ្នាំរួច។ បុណ្យនេះមានរយៈពេលបីថ្ងៃ។ ថ្ងៃទី១ គេហៅថា "ថ្ងៃតាំង" ថ្ងៃទី២ហៅថា "បួសភ្នំ" (ពូននិងបំបួសភ្នំខ្សាច់) និងថ្ងៃទី៣ ហៅថា "ផ្ដាច់ព្រ័ត្រ"។ ការផ្សារបោចផ្ដៅ ជាទូទៅតែងចាប់ផ្ដើមធ្វើមុនថ្ងៃបុណ្យប្រមាណ១ខែ ឬកន្លះខែ។ តាមការសង្កេត ចំពោះការចូលព្រៃបោចផ្ដៅធ្វើព្រ័ត្រនេះ ហាក់ដូចជាកិច្ចសំខាន់មួយដែរចំពោះភូមិស្រុកទាំងមូល មុននឹងបានព្រ័ត្រសម្រាប់លេងថ្វាយអ្នកតា ពោលគឺពុំមែនដើម្បីគ្រាន់តែយកមកធ្វើជាព្រ័ត្រសម្រាប់លេងធម្មតាឡើយ ដ្បិតកិច្ចការនេះត្រូវមានការចូលរួមពីចាស់ទុំ និងអ្នកភូមិ តាំងពីចូលព្រៃបោចផ្ដៅ រហូតដល់ចប់បុណ្យ (រូបលេខ១)។ ទន្ទឹមនឹងនេះ យើងសង្កេតឃើញមានកិច្ចសែន(?) បន្តិចបន្តួចក្នុងព្រៃផ្ដៅ មុននឹងចាប់ផ្ដើមបោចផងដែរ (រូបលេខ២)។

[២] សូមអាន៖ "ផ្ដាច់ព្រ័ត្រ" ដោយ ស៊ីយ៉ុន សុភារិទ្ធ ផ្សាយលើគេហទំព័រយសោធរ http://www.yosothor.org/publications/khmer-renaissance/chapter-six/Proat.html

[៣] សូមអាន៖ "ឧទាហរណ៍៣អំពី "ការទាញក្នុងពិធីឡើងអ្នកតានៅខេត្តកំពង់"" ដោយ ម៉ង់ វ៉ាលី ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/3997 ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១ អ្នកស្រុកលើកគ្នាទៅបោចផ្តៅធ្វើព្រ័ត្រ



រូបលេខ២ អ្នកស្រុកច្រូចសុំសុខសប្បាយក្នុងព្រៃបោចផ្តៅ

ព្រៃដែលជាប្រភពផ្តៅ គឺស្ថិតនៅចម្ងាយប្រមាណ២គីឡូម៉ែត្រពីភូមិ ហើយជាព្រៃដែលអ្នកភូមិចេញចូលដើម្បីរកវល្លិ៍ រកបន្លែ កាប់ស្លឹកជ្រៃ[៦] រកឧស ឬបេះផ្លែផ្តៅលក់ដូរជាដើម។ ព្រៃនេះជាទ្រព្យរួមរបស់អ្នកស្រុក ដែលមានផ្ទៃដីទំហំប្រហែលជាង១ហិកតា តែវាជាប្រភេទព្រៃរនាម លិចទឹកក្នុងរដូវវស្សា និងមានដើមឈើចម្រុះដុះលាយឡំជាមួយផ្តៅ។ ពីដើមមក ផ្តៅដែលអាចកាប់យកមកប្រើសម្រាប់ធ្វើព្រ័ត្រមានពីរប្រភេទ "ផ្តៅទឹក" និង"ផ្តៅក្រែក"។[៧] ប៉ុន្តែបច្ចុប្បន្ន ប្រភេទផ្តៅក្រែកពុំសូវសម្បូរឡើយ ដូច្នេះគេតែងយកផ្តៅទឹកតែម្យ៉ាងគត់មកវេញធ្វើព្រ័ត្រ។ ឈ្មោះឡាតាំងផ្តៅប្រភេទនេះគឺ *"Calamus viminalis"* ជាប្រភេទផ្តៅមានដើមតូច ហើយច្រើនដុះលូតវារឡើងដើមឈើផ្សេងៗក្បែរគុម្ពរបស់វា ដែលអាចកាប់យកប្រើការបានចាប់ពីវាលូតបានប្រវែងប្រហែល៥ម៉ែត្រឡើងទៅ ពោលគឺដុះលូតលាស់បានរវាងពី១ឆ្នាំ ឬ២ឆ្នាំលើស (រូបលេខ៣-៤)។

---

[៦] សូមអានៈ "ជ្រៃ" ស៊ីយ៉ុន សុភារិទ្ធ, ជី វដ្ឋា, សាន ផល្លា, ស៊ុន ចាន់ដឹប, រិន ឡៃជួ ផ្សាយលើគេហទំព័រយសោធរ http://www.yosothor.org/publications/khmer-renaissance/chapter-five/chhrey.html

[៧] សូមអានៈ "ព្រ័ត្រផ្តៅ" ដោយ ស៊ីយ៉ុន សុភារិទ្ធ, ជី វដ្ឋា, សាន ផល្លា, ស៊ុន ចាន់ដឹប, រិន ឡៃជួ ផ្សាយលើគេហទំព័រយសោធរ http://www.yosothor.org/publications/khmer-renaissance/chapterfive/prot-pdav.html

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត



រូបលេខ១៣-៤ ពពួកផ្តៅទឹកដុះវារឡើងព្រៃ ដែលអាចបោចវេញធ្វើព្រ័ត្របាន

ចំពោះផ្តៅបោចបាន បើចាស់ទុំមើលឃើញសន្មតថាគ្រប់ចំនួនហើយ គេត្រូវចងបាច់ដឹកជញ្ជូនមកហាលនៅក្នុងភូមិភ្លាមៗ មុនដល់កំណត់ថ្ងៃវេញធ្វើជាព្រ័ត្រ (រូបលេខ៥)។ ចំនួនផ្តៅដែលគេត្រូវការប្រើជាមធ្យមសម្រាប់ធ្វើព្រ័ត្រមួយខ្សែប្រវែងពី៤០ ទៅ៤៥ ម៉ែត្រ គឺត្រូវការផ្តៅប្រហែល១០ចន្ទាស ឬ១ក្រពើ ពោលគឺចន្លោះពី១០០ ទៅ២០០ដើម[៦] ហើយត្រូវការពេលបោចប្រហែល១ថ្ងៃ ទៅ២ ថ្ងៃទើបគ្រប់តម្រូវការ។

រីឯការហាលផ្តៅទាំងអស់ខាងលើនេះ គឺត្រូវការពេលប្រហែល២ ទៅ៣ថ្ងៃ ទើបដើមផ្តៅស្រពាប់ទន់ ហើយងាយស្រួលវេញ។ ចំណែកឯបច្ចេកទេសវេញផ្តៅ គេត្រូវពឹងផ្អែកលើចាស់ទុំណែនាំច្រើន ដ្បិតការវេញផ្តៅមួយដើមៗបញ្ចូលគ្នា ត្រូវការបច្ចេកទេសចងរឹតឱ្យជាប់មាំជាទីបំផុត។ ប៉ុន្តែមុននឹងវេញ គេត្រូវយកផ្តៅមួយដើមៗមកលួសសម្អាតចិញ្ចើមស្វា(ថ្នាំង)ឱ្យស្អាត ដើម្បីកុំឱ្យមុតដៃនៅពេលទាញព្រ័ត្រ។ បន្ទាប់មក គេត្រូវយកផ្តៅខ្លះទៅពុះជាពីរចម្រៀកសម្រាប់ធ្វើចំណង។ ការងារពុះច្រៀកផ្តៅនេះ តែងតែជាភារៈរបស់មនុស្សចាស់ ដ្បិតពួកគាត់ស្ទាត់ប្រើកាំបិតបន្ទស់ផង និងចេះលៃប្រមាណច្រៀកបានស្មើសាច់ល្អផង (រូបលេខ៦-៧)។

[៦] ក្នុងខ្នាតបុរាណគេរាប់ចំនួនផ្តៅជា "គូ" "ចន្ទាស" និង "ក្រពើ"។ ១គូ = ២ដើម, ១ចន្ទាស = ១០គូ (២០ដើម), ១ក្រពើ = ១០ចន្ទាស (២០០ដើម)។ ខ្នាតនេះ គេក៏ប្រើក្នុងការទិញដូរផ្តៅដែរ គឺ១ចន្ទាស តម្លៃប្រហែល២០ ទៅ២៥ រៀល (ប្រហែលក្នុងឆ្នាំ១៩៥០)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២៥ អ្នកភូមិជញ្ជូនផ្តៅចេញពីព្រៃយកទៅហាលមុននឹងវេញធ្វើព្រ័ត្រ



រូបលេខ២៦ ចាស់ៗច្រៀកផ្តៅធ្វើចំណងព្រ័ត្រ



រូបលេខ២៧ ការប្រើកាំបិតបន្ទាស់ច្រៀកផ្តៅ

បន្ទាប់ពីសម្អាតចិញ្ចើមស្វាចប់សព្វគ្រប់ និងបានចម្រៀកសម្រាប់ធ្វើចំណងល្មមគ្រប់គ្រាន់ហើយ គេត្រូវយកផ្តៅមកមូលចុងដើម ចងបន្តគ្នានឹងចំណងស្ទឹកជ្រែបណ្តោះអាសន្នឱ្យបានប្រវែងតាមគេចង់បានសិន (ប្រហែល៤០ម៉ែត្រ)។ ការចងបែបនេះ ត្រូវធ្វើជាពីរខ្សែសម្រាប់វេញធ្វើផ្ទុងមេ ឬផ្ទុងសំខាន់។ បន្ទាប់មក ទើបគេចាប់ផ្តើមស្រាយចំណងស្ទឹកជ្រែនៃខ្សែនីមួយៗ ហើយចងនឹងចំណងចម្រៀកផ្តៅឱ្យល្អ សន្មតយកជាបានការ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដើម្បីវេញបញ្ចូលគ្នាឱ្យកើតជាផ្នុងមេ (រូបលេខ៨)។ ពេលបានផ្នុងសំខាន់ហើយ គេបន្តតផ្តៅផ្សេងៗទៀតវេញជាពីរផ្នុង  រួចយកមកវេញបញ្ចូលនឹងផ្នុងសំខាន់ដំបូងនោះជាបន្តបន្ទាប់ រហូតបានខ្សែព្រ័ត្រតាមទំហំ និងប្រវែងតាមការចង់បានទើបគេឈប់វេញ។ ប៉ុន្តែតាមការសង្កេត ចំណុចពិសេសនៃការវេញបញ្ចូលគ្នានេះ គេត្រូវលៃយ៉ាងណាមិនឱ្យមុខតំណនៃផ្នុងនីមួយត្រួតចំគ្នាឡើយ ហើយដើម្បីកុំឱ្យផ្នុងនីមួយៗរសាយចេញពីគ្នា នៅលើខ្សែព្រ័ត្រដែលសម្រេចនោះ គេត្រូវចងចំណងចម្រៀកផ្តៅចន្លោះពីមួយទៅមួយប្រហែល៣តឹក (រូបលេខ៩) ទើបធានាថាព្រ័ត្រនោះមាំល្អ ធន់នឹងកម្លាំងទាញរបស់ក្រុមមនុស្សម្ខាងៗពី៣០ ទៅ៤០នាក់បាន។ ម្យ៉ាងវិញទៀត ចុងព្រ័ត្រទាំងសងខាង គេត្រូវវេញយ៉ាងណាឱ្យរាវស្តួចតូចទៅរហូតសល់ផ្តៅមួយសរសៃ  ដែលមើលទៅហាក់មិនខុសអ្វីពីកន្ទុយពស់ឡើយ  (រូបលេខ១០)។  លុះស្រេចបាច់អស់ហើយ  គេត្រូវយកក្រណាត់ក្រហមមកចងសម្គាល់នៅចំកណ្តាលខ្សែព្រ័ត្រ (រូបលេខ១១)។



រូបលេខ៨ បច្ចេកទេសវេញព្រ័ត្រ



រូបលេខ៩ ការរឹតចំណងត្រង់មុខតំណសរសៃផ្តៅ



រូបលេខ១០ កន្ទុយព្រ័ត្ររាវស្តួចតូចដូចកន្ទុយពស់



រូបលេខ១១ ព្រ័ត្រវេញរួចមានចំណងក្រហមកណ្តាល

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

មកដល់ថ្ងៃបុណ្យ គេត្រូវរៀបចំធ្វើកិច្ចប្រុងពាលីជាធម្មតានៅវេលាល្ងាច (រូបលេខ១១២)។ បន្ទាប់មកគេពូនភ្នំខ្សាច់ និងបួសភ្នំខ្សាច់ (រូបលេខ១១៣) រួចទើបធ្វើកិច្ចបន្តបន្ទាប់តាមគន្លងព្រះពុទ្ធសាសនា ព្រមទាំងលេងល្បែងរបាំផ្សេងៗ រួមទាំងទាញព្រ័ត្រផងៗ ប៉ុន្តែការទាញព្រ័ត្រក្នុងថ្ងៃទី១ និងថ្ងៃទី២ គេពុំប្រឹងទាញឱ្យដាច់ឡើយ ពោលគឺគ្រាន់តែទាញលេងសប្បាយប៉ុណ្ណោះ។ លុះចូលដល់ថ្ងៃទី៣ ជាថ្ងៃផ្ដាច់ព្រ័ត្រ គេត្រូវយកព្រ័ត្រដែលបាននិយាយហូរហែមកខាងលើ មកទាញជាកិច្ចក្បែរខ្ទមអ្នកតា (រូបលេខ១១៤)។ ការទាញនៅពេលនេះ ម្ខាងជាក្រុមស្រីៗ និងម្ខាងជាក្រុមបុរស ដែលភាគច្រើនជាយុវជនពេញកម្លាំង តែចំនួនមនុស្សក្នុងក្រុមម្ខាងៗពុំស្មើគេដូចរាប់ទេ។ គេត្រូវទាញបីក្ដារដើម្បីផ្ដាច់ព្រ័ត្រនោះ ប៉ុន្តែបើទាញក្នុងក្ដារទី១ ឬក្ដារទី២ ហើយចាស់ទុំមើលឃើញថាមិនដាច់ទេ គេយកកាំបិតមកកាត់ផ្ទុងព្រ័ត្រខ្លះ (រូបលេខ១១៥) ដើម្បីឱ្យទាញដាច់ទៅតាមបំណងជាកិច្ចបញ្ចប់ថ្វាយអ្នកតា។ បន្ទាប់ពីទាញផ្ដាច់ព្រ័ត្រថ្វាយអ្នកតាហើយ ភ្លាមនោះគេនិមន្តព្រះសង្ឃប្រោះព្រំបន្ថែមទៀត ដើម្បីសុំសុខសប្បាយតាមទំនៀម (រូបលេខ១១៦)។



រូបលេខ១១២ កិច្ចប្រុងពាលី

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១៣ កិច្ចពូនភ្នំខ្សាច់និងបំបួសភ្នំខ្សាច់



រូបលេខ១៤ ការទាញដើម្បីផ្ដាច់ព្រ័ត្រក្នុងក្ដារទី៣



រូបលេខ១៥ កាត់ផ្ចុងព្រ័ត្រខ្វះដើម្បីទាញផ្ដាច់ព្រ័ត្រ



រូបលេខ១៦ ព្រះសង្ឃនិមន្តប្រោះព្រំក្រោយផ្ដាច់ព្រ័ត្រ

សូមកុំភ្លេចថា ក្នុងសៀវភៅមហាសង្ក្រាន្តបុរាណៗលោកតែងហៅល្បែងទាញព័ត្រជា "ល្បែងនក្ខត្តឫក្ស" ពោលគឺពុំមែនល្បែងដែលយកលេងល្បងកម្លាំងគ្នាយកឈ្នះចាញ់ក្នុងន័យជាកីឡាឡើយ។ រីឯ "ផ្ដាច់ព្រ័ត្រ" ក្នុងទីនេះគេយល់ថា ជានិមិត្តរូបនៃការដាច់ឆ្នាំចាស់ចូលឆ្នាំថ្មី ពោលគឺបញ្ចប់វដ្ដកសិកម្មចាស់ផ្ដើមចូលវដ្ដកសិកម្មថ្មី។[៧] ចប់ខែចែត្រចូលខែពិសាខ ដែលខ្មែរហៅថា "ដើមឆ្នាំ"។ លើសពីនេះគេដឹងថាល្បែងទាញព្រ័ត្រ មានខ្លឹមសារជ្រៅក្នុងជំនឿពាក់ព័ន្ធនឹងកសិកម្មដាំដុះ របស់ប្រជាជនក្នុងប្រទេសមួយចំនួននៅអាស៊ី។ ហេតុដូច្នេះ ទើបនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៥ ល្បែងទាញព្រ័ត្រ ត្រូវបានចុះបញ្ជីពហុជាតិសាសន៍ក្នុង"បញ្ជីតំណាងនៃបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ"តាមសំណើរួមរបស់កម្ពុជា ហ្វីលីពីន វៀតណាម និងសាធារណរដ្ឋកូរ៉េខាងត្បូង៕

[៧] សូមអាន៖ "ព្រ័ត្រផ្ដៅ" ដោយ ស៊ីយ៉ុន សុភារិទ្ធ, ជី រដ្ឋា, សាន ផល្លា, ស៊ុន ចាន់ដឹប, វិន ឡៅជួ ផ្សាយលើគេហទំព័រយសោធរ http://www.yosothor.org/publications/khmer-renaissance/chapterfive/prot-pdav.html

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ម៉ង់ វ៉ាលី

"ឧទាហរណ៍៣អំពី "ការទាញក្នុងពិធីឡើងអ្នកតានៅខេត្តកំពង់"" ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/3997 ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១

ស៊ីយ៉ុន សុភារិទ្ធ

"ផ្ទាច់ព្រ័ត្រ" ផ្សាយលើគេហទំព័រយសោធរ http://www.yosothor.org/publications/khmer-renaissance/chapter-six/Proat.html

ស៊ីយ៉ុន សុភារិទ្ធ, ជី វដ្ឋា, សាន ផល្លា, ស៊ុន ចាន់ដឹប, រិន ឡៃជួ

"ជ្រៃ" ផ្សាយលើគេហទំព័រយសោធរ http://www.yosothor.org/publications/khmer-renaissance/chapter-five/chhrey.html

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត